សមាគមនិស្សិតខ្មែរនៅប្រទេសជប៉ុន Cambodian Students Association in Japan
គេហទំព័រ http://www.csaj-khmer.org

# ត្រៀមខ្លួនដើម្បីបន្តការសិក្សានៅប្រទេសជប៉ុន

## យោបល់ណែនាំពីសិស្សច្បង

### លេខឆ្នាំ២០០៣

# បុព្វកថា

ជាបឋមតាងនាមសិស្សច្បងដែលកំពុងសិក្សានៅប្រទេសជប៉ុនទាំងអស់ ខ្ញុំបាទសូមចូលរួមអបអរសាទរ ចំពោះជោគជ័យក្នុងការប្រលងរបស់អ្នកទាំងអស់គ្នា និងសូមស្វាគមន៍ចំពោះការមកសិក្សានៅប្រទេសជប៉ុន។ ទន្ទឹមនឹងនោះដែរខ្ញុំបាទសូមអភ័យទោសនូវរាល់ការខុសឆ្គងនិងការខ្វះខាតទាំងឡាយនៅក្នុងការចងក្រងអត្ថបទនេះ។ បើសិនជាអ្នកទាំងអស់គ្នាប្រទះឃើញនូវការខុសឆ្គងត្រង់ចំនុចណាមួយសូមមេត្តាអ៊ីមែលមករូបខ្ញុំបាទដោយផ្ទាល់[១] ។ សូមបញ្ជាក់ថាអត្ថបទណែនាំនេះជាមតិផ្ទាល់ខ្លួនរបស់ខ្ញុំបាទ អាស្រ័យហេតុនេះ ការទទួលខុសត្រូវទាំងឡាយគឺឋិតនៅលើរូបខ្ញុំបាទផ្ទាល់ សមាគមនិស្សិតខ្មែរនៅប្រទេសជប៉ុនមិនមានការទទួលខុសត្រូវនៅលើការខុសឆ្គងទាំងឡាយឡើយ។ អត្ថបទណែនាំនេះគួរប្រើប្រាស់ជាមួយនឹងសៀវភៅណែនាំទាំងឡាយដែលទទួលបានពីស្ថានទូតជប៉ុនប្រចាំនៅប្រទេសខ្មែរ ដូចជាសៀវភៅ “**Life and Study in Japan**”។ សំរាប់អ្នកដែលមានលទ្ធភាពប្រើInternet សូមព្យាយាមធ្វើការស្វះស្វែងរកពិតមានតាមរយៈគេហទំព័រនានា ដូចជាគេហទំព័ររបស់**AIEJ**[2] ឬក៏គេហទំព័ររបស់សកលវិទ្យាល័យនានា។បើអាចធ្វើទៅបាន សូមអ្នកទាំងអស់គ្នាធ្វើការសាកសួរពិតមានពីសំនាក់និស្សិតដែលបានបញ្ចប់ការសិក្សានៅប្រទេសជប៉ុនហើយវិលត្រលប់ទៅប្រទេសខ្មែរវិញ[៣] ឬពីសំនាក់និស្សិតកំពុងបំពេញការសិក្សានៅប្រទេសជប៉ុនដែលត្រលប់ទៅលេងស្រុក។រាល់ចំងល់ទាំងឡាយអាចសួរមករូបខ្ញុំបាទផ្ទាល់តាមរយៈ អ៊ីមែល ឬតាមរយៈBBSរបស់គេហទំព័រសមាគម។

ធ្វើនៅតូក្យូ ថ្ងៃទី២១ខែមករាឆ្នាំ២00៣

អ្នករៀបរៀង

លឹម វិសាល

---

1 អាស័យដ្ឋានអ៊ីមែលរបស់ខ្ញុំបាទគឺ ilovecsaj@yahoo.com

2 http://www.aiej.or.jp

3 សូមធ្វើការទាក់ទងជាមួយសមាគមអតីតនិស្សិតខ្មែរនៅប្រទេសជប៉ុន

# ការថ្លែងអំណរគុណ

ជាបឋមខ្ញុំបាទសូមថ្លែងអំណរគុណដល់លោក ឡុង សូផាត ដែលបានផ្តួចផ្តើមគំនិតបង្កើតអត្ថបទនេះឡើង។ ជាមួយគ្នានេះផងដែរខ្ញុំបាទសូមថ្លែងអំណរគុណដល់សមាជិកសមាគមនិស្សិតខ្មែរនៅប្រទេសជប៉ុនដែលបានគាំទ្រលើកទឹកចិត្តដល់រូបខ្ញុំបាទក្នុងការរៀបរៀងអត្ថបទនេះ ។ជាងនេះទៅទៀត ខ្ញុំបាទ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់និស្សិតទាំងអស់ដែលបានជួយផ្តល់ជាយោបល់ដល់រូបខ្ញុំបាទ ដូចមានរាយនាមខាងក្រោមនេះ លោក ង៉ូវ ប៉េងហ៊ុយ កញ្ញា ខាក ចិន្តា លោក ហែម វ៉ាន់ឌី លោក ជូ ប៊ុនហៀង លោក ហេង សេងលី កញ្ញា ប៉ុក ណារី លោក លីតុង លោក លឹម សុវណ្ណារ៉ា លោក ទេព វិចិត្រ លោក ស៊ឹម វីរៈ លោក ឡុង សូផាត លោក ញាន តុលា កញ្ញា ណុម សុធារី កញ្ញា អួន ភ័ក្តនី លោក អែម ចំណាប់ និង លោក សុខ ថងឌី។

ធ្វើនៅតូក្យូ ថ្ងៃទី២១ខែមករាឆ្នាំ២០០៣

អ្នករៀបរៀង

លឹម វិសាល

# I ផ្នែកទី១ យោបល់ណែនាំទូទៅពីសំណាក់អ្នករៀបរៀង

## ១. តើយើងត្រូវធ្វើអ្វីខ្លះមុនពេលចេញដំណើរមកប្រទេសជប៉ុន?

អ្នកទាំងអស់គ្នាគួរតែរៀនភាសាជប៉ុនខ្លះ និងរៀនអ្វីដែលទាក់ទងនឹងមុខជំនាញរបស់ខ្លួន ។ឧទាហរណ៍ អ្នកដែលមករៀនខាងសេដ្ឋកិច្ចគួររៀនត្រៀមគណិតវិទ្យាខ្លះដូចជា Calculus, Linear Algebra, Statistics ជាដើម ។ទោះបីជាអ្នកនឹងអស់គ្នានឹងមានឱកាសរៀនភាសាជប៉ុនក្រោយពេលមកដល់ប្រទេសជប៉ុនក៏ដោយ អ្នកទាំងអស់គ្នាគួរតែរៀនភាសាជប៉ុនខ្លះមុននឹងចេញដំនើរមក ។អានសៀវភៅអំពីប្រទេសជប៉ុនខ្លះ បើអាចធ្វើទៅបាន ។បន្តការសិក្សាភាសាអង់គ្លេសព្រោះអ្នកទាំងអស់គ្នានឹងត្រូវប្រើប្រាស់វាក្រោយពេលមកដល់ប្រទេសជប៉ុនទាំងក្នុងជីវភាពរស់នៅនិងក្នុងការសិក្សា ។ព្យាយាមប្រមូលឯកសារដែលទាក់ទងទៅនឹងមុខជំនាញរបស់ខ្លួនជាពិសេសអ្នកដែលសិក្សាជំនាញទាក់ទងទៅនឹងស្រុកខ្មែរ ពីព្រោះឯកសារដែលទាក់ទងទៅនឹងស្រុកខ្មែរមានតិចតួចណាស់នៅប្រទេសជប៉ុន ។

## ២. តើយើងត្រូវយកអ្វីខ្លះមកជាមួយ?

១. សំលៀកបំពាក់ កុំយកសំលៀកបំពាក់មកច្រើនពេកព្រោះអ្នកទាំងអស់គ្នាអាចទិញនៅប្រទេសជប៉ុនបាន ។ កន្លងមកនិស្សិតយើងច្រើនតែយកសំលៀកបំពាក់មកច្រើនពេក ជាពិសេសអាវរងារ ។អាវរងារដែលយកមកពីស្រុកខ្មែរច្រើនខុសពីអាវរងារទិញនៅប្រទេសជប៉ុន ។អាវរងារស្រុកខ្មែរច្រើនមានគុណភាពមិនសូវល្អហើយពាក់មកចូលគេមិនចុះព្រោះវាខុសពីគេ ។គួរយកសំលៀកបំពាក់ប្រពៃណីមួយសំរាប់មកជាការល្អ ព្រោះអ្នកទាំងអស់គ្នានឹងត្រូវការវាក្នុងឱកាសផ្សេងៗដូចជា ពិធីបុណ្យវប្បធម ពិធីជប់លៀងផ្សេងៗ ។ល ។ ចំពោះបុរស ដាច់ខាតត្រូវការអាវធំមួយសំរាប់ ប៉ុន្តែអ្នកទាំងអស់គ្នាអាចទិញនៅជប៉ុនបាន ។តំលៃអាវធំមួយសំរាប់មានចាប់ពី ១៥,000យ៉េនឡើងទៅ ជាមធ្យមតំលៃប្រហែលពីរបីម៉ឺនយ៉េន ។

២. សៀវភៅនិងសម្ភារៈសិក្សា វចនានុក្រមជប៉ុន-ខ្មែរត្រូវការប្រើសំខាន់ក្នុងកំឡុងពេលមកដល់ដំបូងមុនពេលទិញវចនានុក្រមអេឡិចត្រូនិច( ជប៉ុន-អង់គ្លេស+អង់គ្លេស-ជប៉ុន) ។អ្នកទាំងអស់គ្នានឹងត្រូវការវាជាចាំបាច់

បើសិនជាមិនចង់ទិញវចនានុក្រមអេឡិចត្រូនិចទេ ប៉ុន្តែខ្ញុំគិតថាអ្នកទាំងអស់គ្នានឹងទិញវចនានុក្រមអេឡិចត្រូនិចមិនខានព្រោះអ្នកដែលមកជំនាន់មុនៗទិញស្ទើរតែគ្រប់ៗគ្នា ។ដូចគ្នានេះដែរ វចនានុក្រមខ្មែរ-ជប៉ុនត្រូវការប្រើសំខាន់ក្នុងកំឡុងពេលមកដល់ដំបូង ។វចនានុក្រមអង់គ្លេស ក៏ត្រូវការប្រើជាសំខាន់ដែរ ព្រោះអ្នកទាំងអស់គ្នានឹងត្រូវប្រើភាសាអង់គ្លេសក្នុងការសិក្សាភាសាជប៉ុន និងមុខវិជ្ជាជំនាញសំរាប់វគ្គសិក្សាខ្លះ ។វចនានុក្រមអង់គ្លេស-អង់គ្លេសអាចទិញបាននៅជប៉ុន ជាពិសេសវចនានុក្រមអេឡិចត្រូនិចចេញសេរីក្រោយៗនេះមានគ្រប់មុខងារទាំងអស់ ជប៉ុន-អង់គ្លេស អង់គ្លេស-ជប៉ុន ជប៉ុន-ជប៉ុន និង អង់គ្លេស-អង់គ្លេស ។ចំពោះសៀវភៅជំនាញវាពិបាកនឹងនិយាយណាស់ថាតើអ្នកទាំងអស់គ្នាត្រូវការសៀវភៅអ្វី ដូច្នេះ សូមអ្នកទាំងអស់គ្នាយកសៀវភៅណាដែលយល់ថាទាក់ទងនឹងជំនាញរបស់ខ្លួនមក ។ឧទាហរណ៍ និស្សិតដែលមក សិក្សាផ្នែកឧត្តមសិក្សាខាងសេដ្ឋកិច្ចនឹងត្រូវការសៀវភៅគណិតវិទ្យាដូចជា ដេរីវេ អាំងតេក្រាល ម៉ាទ្រីស ប្រូបាប៊ីលីតេ ស្ថិតិ ។ល ។អ្នកទាំងអស់គ្នាមិនចាំបាច់យកសៀវភៅរៀនភាសាជប៉ុនមកជាមួយទេ ព្រោះសៀវភៅទាំងអស់នោះមិនខ្វះទេនៅជប៉ុន អ្នកទាំងអស់គ្នាអាចទទួលបានពីសាលា ខ្ចីពីសិស្សច្បង ឬក៏ទិញខ្លួនឯងក៏បាន ។

៣. វត្ថុវប្បធម៌ អ្នកទាំងអស់គ្នាគួរតែយកវត្ថុវប្បធម៌មកខ្លះព្រោះអ្នកទាំងអស់គ្នានឹងត្រូវបង្ហាញពីវប្បធម៌ខ្មែរដល់ជនជាតិជប៉ុននិងជនជាតិបរទេសផ្សេងៗ ។ជាងនេះទៅទៀត វត្ថុអស់ទាំងនោះគឺជាវត្ថុអនុស្សាវរីយ៍ដ៏ល្អបំផុត ។វត្ថុអនុស្សាវរីយ៍អាចជា កាំប៉ុស្តាល់ ផ្ទាំងគំនូរ រូបអាប់សារ៉ា រូបអង្គរវត្ត អាវយឺតគ្រឿងផ្តៅ ។ល ។ អ្នកទាំងអស់គ្នាគួរតែយកទង់ជាតិនិងផែនទីមួយមកជាមួយផងជាការល្អ ។

៤. ចំនីអាហារ អ្នកទាំងអស់គ្នាគួរតែយកគ្រឿងចំនីអាហារក្រៀមក្រោះមកតែបន្តិចបានហើយ កុំយកមកច្រើនពេកព្រោះអ្នកទាំងអស់គ្នានឹងញុាំវាតែក្នុងកំឡុងពេលប៉ុន្មានថ្ងៃដំបូងប៉ុណ្ណោះ ។អ្នកដែលចេះធ្វើម្ហូបអាចយកប្រហុក ផ្អក អំពិលទុំ ។ល ។មកជាមួយបាន ។ មិនចាំបាច់យកទឹកស៊ីអីវ ទឹកត្រីមកជាមួយទេ ព្រោះទីមួយវាធ្ងន់ហើយងាយបែក ទីពីរវាអាចទិញនៅជប៉ុនបាននៅតាមកន្លែងខ្លះ ហើយមិនជាថ្លៃពេកណាស់ទេ ។

៥. ស៊ីឌីនិងកាសែតចំរៀង អ្នកទាំងអស់គ្នាគួរតែយកស៊ីឌីនិងកាសែតចំរៀងមកខ្លះដើម្បីទុកស្តាប់ព្រោះ

ថារបស់អស់ទាំងនោះមិនអាចរកទិញបានទេនៅជប៉ុន ។របស់អស់ទាំងនោះអាចជួយបំបាត់ការអផ្សុករបស់អ្នកទាំងអស់គ្នាបានខ្លះ ។បទចំរៀងរាំវង់រាំក្បាច់ក៏គួរយកមកខ្លះដែរដើម្បីប្រើក្នុងពិធីបុណ្យផ្សេងៗ ។

## ៣. យោបល់បន្ថែមទៅលើសៀវភៅLife and Study in Japan[4]

អ្នកទាំងអស់គ្នាគួរតែអានសៀវភៅនេះអោយបានច្បាស់ ព្រោះសៀវភៅនេះមានពិតមានចាំបាច់ដែលអ្នកទាំងអស់គ្នាត្រូវការស្ទើរតែទាំងអស់ ។នៅក្នុងឱកាសនេះខ្ញុំបាទសូមធ្វើការបញ្ចេញយោបល់បន្ថែមទៅលើចំនុចខ្វះខាតរបស់សៀវភៅនេះ ។សូមអ្នកទាំងអស់គ្នាអានអត្ថបទនេះផ្ទៀងជាមួយសៀវភៅនោះផង ។

៣.១ ត្រង់ជំពូកទី១.៣ Preparing for departure ទំព័រទី៩[៥] ត្រង់ចំនុចPhotograph

កុំយករូបថតមកច្រើនពេក យកមកត្រឹមដប់សន្លឹកជាងទៅម្ភៃសន្លឹកបានហើយ ព្រោះនៅជប៉ុនគេច្រើនប្រើរូបថតថ្មីៗថតក្នុងកំឡុងពេល៦ខែ ហើយនៅជប៉ុនអ្នកទាំងអស់គ្នាអាចថតរូបនៅតាមម៉ាស៊ីនដែលមាននៅគ្រប់កន្លែងបានដោយងាយ ។

៣.២ ត្រង់ជំពូកទី១.៣ Preparing for departure ទំព័រទី៩ត្រង់ចំនុចMoney

អ្នកទាំងអស់គ្នាប្រហែលជាមិនត្រូវការយកលុយមកដល់ទៅ១,000ដុល្លាទេមើលទៅ ។សំរាប់រូបខ្ញុំផ្ទាល់ ខ្ញុំបានយកប្រាក់មកចំនួន១,000ដុល្លាដែរ តែត្រូវការដូរចាយដំបូងតែ៣00ដុល្លាប៉ុណ្ណោះ ។ខ្ញុំគិតថា៥00ដុល្លាប្រហែលជាគ្រប់គ្រាន់ហើយ ។សំរាប់អ្នកដែលខ្វះខាតខ្លាំងគ្មានលទ្ធភាពសោះអាចទាក់ទងខ្ចីពីសិស្សច្បងបានខ្លះ[៦] ប្រសិនបើជាមានការខ្វះខាតខ្លាំងមែនទែន សមាគមអាចនឹងមានវិធានការជួយអោយខ្ចីខ្លះដែរ ។

៣.៣ ទំព័រទី១១ត្រង់ចំនុចUnaccompanied Baggage

ភ្លើងអគ្គិសនីនៅជប៉ុនគឺ១១0វ៉ុល ដូច្នេះគ្រឿងអគ្គិសនីដែលយកមកពីស្រុកខ្មែរត្រូវការadaptor ។

---

4 សៀវភៅនេះត្រូវបានចែកអោយដោយស្ថានទូតជប៉ុននៅស្រុកខ្មែរដល់និស្សិតអាហារូបករណ៏Monbushooទាំងអស់ ។ ខ្ញុំបាទ បានអានសៀវភៅសំរាប់និស្សិតJDSដែរតែមិនឃើញមានអ្វីសំខាន់ដែលត្រូវបន្ថែម ។

5 លេខទំព័ររបស់ខ្ញុំអាចនឹងខុសពីលេខទំព័ររបស់អ្នកទាំងអស់គ្នាព្រោះសៀវភៅរបស់ខ្ញុំចេញឆ្នាំ២00២ ។

6 ចំពោះអ្នកដែលទៅតាមខេត្តឆ្ងាយៗប្រហែលជាមិនអាចទាក់ទងខ្ចីពីសិស្សច្បងទេព្រោះនៅខេត្តខ្លះគ្មានសិស្សច្បងទេ ។

៣.៤ ទំព័រទី១៥ត្រង់ចំនុចContact the University Academic Advisor

និស្សិតដែលមកសិក្សាវគ្គមួយចំនួនដូចជាវគ្គឧត្តម វគ្គមធ្យម វគ្គបណ្តុះបណ្តាលវិជ្ជាជីវៈ មិនចាំបាច់ទាក់ទងជាមួយគ្រូទទួលបន្ទុកទេ ។អ្នកទាំងនោះក៏មិនទាន់មានគ្រូទទួលបន្ទុកនៅឡើយដែរ ។

៣.៥ ទំព័រទី២៥ត្រង់ចំនុចHousing

អ្នកទាំងអស់គ្នាមិនបាច់បារម្ភពីបញ្ហាកន្លែងស្នាក់នៅទេ ព្រោះនិស្សិតភាគច្រើននឹងត្រូវស្នាក់នៅអន្តេវាសិកដ្ឋាន ចំនែកឯនិស្សិតមួយចំនួនតូចដែលមិនអាចស្នាក់នៅអន្តេវាសិកដ្ឋានបានហើយត្រូវជួលផ្ទះដោយខ្លួនឯងនឹងត្រូវបានសាលានិងស្ថាប័នទទួលបន្ទុកជួយដោះស្រាយ ។

៣.៦ ទំព័រទី៤១ត្រង់ចំនុចPart-time Work

និស្សិតអាហារូបករណ៍JDS មិនអាចធ្វើការងារក្រៅម៉ោងបានទេ ចំនែកឯនិស្សិតអាហារូបករណ៍Monbushoo អាចធ្វើការងារក្រៅម៉ោងបាន ។បើតាមច្បាប់អ្នកដែលចង់ធ្វើការក្រៅម៉ោងត្រូវសុំច្បាប់ពីនាយកដ្ឋានអន្តោប្រវេសន៏ ប៉ុន្តែកន្លងមកនិស្សិតដែលធ្វើការក្រៅម៉ោងស្ទើរតែទាំងអស់មិនដែលបានសុំច្បាប់ធ្វើការទេ ។បើតាមយោបល់ផ្ទាល់ខ្លួន ខ្ញុំបាទយល់ថាអ្នកទាំងអស់គ្នាមិនចាំបាច់គិតពីរឿងធ្វើការក្រៅម៉ោងទេពេលមកដល់ដំបូង គួរតែចំណាយពេលទៅលើការរៀនសូត្រសិនព្រោះ ទី១ប្រាក់ខែរបស់អ្នកទាំងអស់គ្នាវាគ្រប់គ្រាន់សំរាប់ការចាយវាយជាធម្មតារ ទីពីរអ្នកទាំងអស់គ្នាមិនទាន់ចេះភាសាជប៉ុនច្រើននៅឡើយ ។ចំពោះនិស្សិតវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈជាដើមដែលត្រូវការលុយដើម្បីបន្តការសិក្សាក្រោយពេលចប់វគ្គសិក្សា ហើយត្រូវការធ្វើការបន្ថែមនោះអាចចាប់ផ្តើមធ្វើការពីឆ្នាំទីពីរទៅបាន ។

៣.៧ ទំព័រទី៤៥ត្រង់ចំនុចExtension of Scholarship Tenure

និស្សិតអាហារូបករណ៏ Monbushoo វគ្គក្រោយឧត្តម វគ្គឧត្តមនិងវគ្គមធ្យមអាចសុំបន្តអាហារូបករណ៏បាន ។និស្សិតវគ្គក្រោយឧត្តមអាចបន្តពីវគ្គMasterទៅDoctor បាន ។ចំនែកនិស្សិតវគ្គឧត្តមអាចបន្តទៅវគ្គMaster បាន ។ រីឯនិស្សិតវគ្គមធ្យមអាចបន្តទៅមហាវិទ្យាល័យដោយចាប់ផ្តើមពីឆ្នាំទី៣ទៅ ។បើតាម

លទ្ធផលកន្លងមក និស្សិតវគ្គក្រោយឧត្ដមនិងវគ្គឧត្ដមដែលចង់បន្តអាហារូបករណ៍ភាគច្រើនអាចបន្ត អាហារូបករណ៍បាន ចំនែកឯវគ្គមធ្យមមានការលំបាកបន្តិច ។អ្នកដែលមិនអាចបន្តអាហារូបករណ៍ Monbushoo បានអាចស្វែងរកអាហារូបករណ៍ផ្សេងៗបាន ។

៣.៨ ទំព័រទី៧៧ត្រង់ចំនុចMedical Fee Reimbursement for International Students

អ្នកដែលបង់ធានារ៉ាប់រងត្រូវបង់ប្រាក់ថ្លៃពេទ្យតែ៣០%នៃតំលៃទាំងអស់ ហើយអាចទទួលបាននូវការឧបត្ថម្ភពីសាលាវិញចំនួន៨០%នៃប្រាក់ដែលបានបង់ហើយ[៧] ។ដូច្នេះអ្នកដែលបានបង់ធានារាប់រងត្រូវបង់ប្រាក់តែ៦%នៃថ្លៃព្យាបាលសរុបប៉ុណ្ណោះ ។សំរាប់អ្នកដែលមិនបានបង់ប្រាក់ធានារ៉ាប់រងមិនអាចទទួលបាននូវការឧបត្ថម្ភពីខាងធានា រ៉ាប់រងនិងពីសាលាបានទេ ។ជាយោបល់របស់ខ្ញុំបាទផ្ទាល់ និស្សិតទាំងអស់គួរតែចូលបង់ប្រាក់ធានារ៉ាប់រង ព្រោះ បើសិនជាត្រូវទៅពេទ្យអ្នកទាំងអស់គ្នាត្រូវទទួលបន្ទុកបង់ថ្លៃព្យាបាលតែ៦%ប៉ុណ្ណោះ ហើយប្រាក់ធានារាប់រងក៏មិនជាថ្លៃដែរ ។កន្លងមកមាននិស្សិតខ្មែរយើងមួយចំនួនឈឺធ្ងន់ដល់ថ្នាក់វះកាត់ ដូច្នេះបើសិនជាមិនបានបង់ធានារ៉ាប់រងទេ គឺគ្មានលទ្ធភាពបង់ថ្លៃព្យាបាលទេ ។

៣.៩ ទំព័រទី៨៣ត្រង់ចំនុចEarthquakes

អ្នកទាំងអស់គ្នាមិនបាច់ព្រួយបារម្ភអំពីរឿងរញ្ជួយដីទេ ព្រោះរញ្ជួយដីធំៗដែលបណ្ដាលអោយមានការបាក់ផ្ទះសម្បែង ឬគ្រោះថ្នាក់ដល់អាយុជីវិតនោះគឺកំរកើតមានណាស់ ។ចំពោះរូបខ្ញុំបាទផ្ទាល់ដែលបាននៅប្រទេសជប៉ុនជិត៥ឆ្នាំហើយ បានជួបរញ្ជួយដីដែលមានកំរិតខ្លាំងអាចអោយយើងដឹងបានតែបីបួនដងប៉ុណ្ណោះ ។រញ្ជួយដីភាគច្រើនដែលកើតឡើងគឺមានកំរិតស្រាលបំផុតដល់ថ្នាក់យើងមិនទាំងដឹងខ្លួនផង ។គួររំលឹកថាការរញ្ជួយដីធំៗដូចការរញ្ជួយដីនៅទីក្រុងកូបេកាលពីឆ្នាំ១៩៩៥នោះគឺកើតឡើងក្នុងកំឡុង១០០ឬ២០០ឆ្នាំម្ដងតែប៉ុណ្ណោះ ។

៣.១០ ទំព័រទី៩១ត្រង់ចំនុចOpening a Bank Account

---

7 តាមពិតប្រាក់ឧបត្ថម្ភនេះជារបស់AIEJទេ តែយើងត្រូវធ្វើពាក្យសុំតាមរយៈសាលា ។

អ្នកទាំងអស់គ្នាមិនបាច់ព្រួយបារម្ភពីរឿងបើកកុងធនាគារទេ ព្រោះនៅជប៉ុនការបើកកុងធនាគារគឺងាយជាងការញ៉ាំបាយទៅទៀត ។និស្សិតភាគច្រើនមានកុងធនាគារដល់ទៅបីបួនឯណោះ ។

៣.១១ ទំព័រទី៩៣ត្រង់ចំនុចTelephone

អ្នកទាំងអស់គ្នាគួរតែសាកសួរនិស្សិតដែលមកមុនៗពីការទូរស័ព្ទទៅស្រុកខ្មែរ ព្រោះថានៅជប៉ុនមានក្រុមហ៊ុនទូរស័ព្ទច្រើនដែលផ្តល់សេវាក្នុងតំលៃខុសៗគ្នា ។ ចំនែកឯការភ្ជាប់ទូរស័ព្ទក្នុងស្រុកក៏មិនមានការលំបាកដែរ និស្សិតខ្មែរយើងស្ទើរតែទាំងអស់ប្រើទូរស័ព្ទដៃ ។

៣.១២ ទំព័រទី៩៩ត្រង់ចំនុចTransportation

នៅជប៉ុនការធ្វើដំនើរក្នុងក្រុងនិងទៅទីក្រុងជិតៗភាគច្រើនត្រូវប្រើរថភ្លើង ជូនកាលត្រូវប្រើរថយន្តក្រុង ចំណែកឯការធ្វើដំនើរទៅខេត្តឆ្ងាយៗអាចប្រើរថភ្លើង រថយន្តក្រុង កប៉ាល់ ឬក៏យន្តហោះ ។ប្រព័ន្ធធ្វើដំនើរនៅជប៉ុនមានភាពជឿនលឿនណាស់ ដូច្នេះអ្នកទាំងអស់គ្នានឹងមិនមានបញ្ហាក្នុងការធ្វើដំនើរទេ ។ចៀសវាងការប្រើតាក់ស៊ីបើអាចធ្វើទៅបាន ព្រោះតំលៃតាក់ស៊ីនៅជប៉ុនវាថ្លៃកប់ពពក សូម្បីតែធៀបជាមួយបណ្តាប្រទេសជឿនលឿនដទៃទៀតដូចជា សហរដ្ឋអាមេរិច សហគមអឺរុប ឬអូស្រ្តាលីក៏ដោយ ។

# ៤. យោបល់បន្ថែមផ្សេងៗ

៤.១ ការត្រលប់ទៅលេងផ្ទះ និស្សិតដែលនៅសិក្សានៅប្រទេសជប៉ុនអាចត្រលប់ទៅលេងផ្ទះនៅពេលណាក៏បានប៉ុន្តែត្រូវចេញសោហ៊ុយដោយខ្លួនឯង ។ចំពោះនិស្សិតអាហារូបករណ៍JDS ត្រូវសូមការអនុញ្ញាត្តិពីJice ។

៤.២ Internet និស្សិតអាហារូបករណ៍Monbushooវគ្គក្រោយឧត្តមនិងវគ្គឧត្តមមាន Internet ប្រើនៅសាលា ប៉ុន្តែនិស្សិតវគ្គមធ្យមនិងវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈមិនមាន Internet នៅសាលាទេនាឆ្នាំដំបូង ។ចំពោះនិស្សិតអាហារូបករណ៍JDSអាចប្រើ Internet នៅសាលាបាន ។ ក្រៅពីនេះអ្នកទាំងអស់គ្នាក៏អាចទាក់ទងភ្ជាប់ Internet នៅផ្ទះបានដែរ ។

## ៥. យោបល់ណែនាំពីសិស្សច្បងនានា[8]

- ង៉ូវ ប៉េងហ៊ុយ (Fukui University)

រៀនភាសាជប៉ុនអោយបានច្រើន ។ព្យាយាមរកមិត្តភ័ក្រ្តជប៉ុនដើម្បីហាត់និយាយភាសាជប៉ុននិងទទួលបានពិតមានផ្សេងៗ ។

- លី តុង (Utsunomiya University)

ព្យាយាមរៀនភាសាជប៉ុនមែនទែន ។ព្យាយាមរកមិត្តភ័ក្រ្តអោយបានច្រើនក្រោយពីមកដល់ជប៉ុន ។កុំយករបស់របរមកច្រើនពេកព្រោះ របស់ភាគច្រើនអ្នកទាំងអស់គ្នាអាចរកទិញនៅជប៉ុនបាន ។

- ទេព វិចិត្រ (Osaka University)

ពង្រឹងទំនាក់ទំនងជាមួយអ្នកដែលត្រូវមកជាមួយគ្នា ។ត្រៀមខ្លួនសំរាប់ការរស់នៅម្នាក់ឯង ។

- លឹម សុវណ្ណារ៉ា (Kobe University)

រៀនភាសាជប៉ុនអោយបានច្រើន ។កុំយកសំលៀកបំពាក់មកច្រើនពេក អ្នកទាំងអស់គ្នាអាចទិញនៅជប៉ុនបាន ។ អ្នកទាំងអស់គ្នានឹងមើលទៅដូចជាជនចំឡែកនៅក្នុងក្រុង បើសិនជាអ្នកទាំងអស់គ្នាពាក់របស់មកពីស្រុកខ្មែរ ។យ៉ាងហោចណាស់ក៏អាហារូបករណ៍របស់អ្នកទាំងអស់គ្នា វាគ្រប់គ្រាន់សំរាប់ទិញអាវរងារដែរ ។

- ឡុង សូផាត (Nagoya University)

ព្យាយាមស្គាល់សិស្សច្បងអោយបានច្រើន ។កុំព្យាយាមនៅម្នាក់ឯង ។

- ញាន តុលា (Waseda University)

ថែរក្សាសុខភាព ។កុំសប្បាយជ្រុល រឺក៏ប្រឹងជ្រុល ។

- ហែមវ៉ាន់ឌី (International University of Japan)[9]

---

[8] ខ្ញុំបាទសូមអភ័យទោសទៅដល់ម្ចាស់ខ្លួនទាំងអស់បើសិនជាមានការឆ្គាំឆ្គងក្នុងការបកប្រែមកជាភាសាខ្មែរ ។

[9] បច្ចុប្បន្នធ្វើការនៅស្រុកខ្មែរ ។

អ្នកដែលមកសិក្សាខាងសេដ្ឋកិច្ច ខាងអភិវឌ្ឍន៍ ឬ ខាងជំនាញស្រដៀងគ្នានេះគួរយកមកជាមួយនូវឯកសារស្ថិតិម៉ាក្រូសេដ្ឋកិច្ចមួយចំនួនដូចជា

- Annual Report of NBC (National Bank of Cambodia)
- Monthly Bulletin of Economics (Ministry of Finance)
- Monthly Bulletin of Statistics (Ministry of Finance)
- Economic and Monetary Statistics Review (NBC)
- Cambodia Development Review (CDRI)
- Flash Report on the Cambodian Economy (CDRI)
- Statistical Database of Cambodia, CD-Rom (sold at National Institute of Statistics)
- Economic Blueprint (ADB), or documents from World Bank
- Reports on micro-finance activities in Cambodia (many sources)
- Any relevant laws and regulations that discuss the economic issues of Cambodia.
- លឹម វិសាល (University of Tokyo)

ជំរះបញ្ជីអោយបានច្បាស់មុននឹងមក ។ តើអ្នកទាំងអស់គ្នាយល់ថាវគ្គសិក្សារបស់ខ្លួនវែងពេកឬយ៉ាងណា ។ ☺

សំណាងល្អណា ។

## II ផ្នែកទី២ យោបល់ណែនាំតាមវគ្គសិក្សាពីសំណាក់សិស្សច្បងនានា[១០]

### ១. យោបល់ណែនាំសំរាប់និស្សិតអាហារូបករណ៍វគ្គឧត្តមសិក្សា ដោយសិស្សច្បងវគ្គឧត្តមសិក្សា លឹម វិសាល

និស្សិតដែលមកសិក្សាវគ្គឧត្តមសិក្សាត្រូវបានបែងចែកជាពីរក្រុម ។ក្រុមទីមួយត្រូវទៅសិក្សាភាសាជប៉ុននៅសាលាTokyo University of Foreign Studies, Japanese Language Center ចំណែកឯក្រុមទីពីរត្រូវទៅសិក្សាភាសាជប៉ុននៅសាលាOsaka University of Foreign Studies, Japanese Language Center ។នៅសាលាភាសាជប៉ុនអ្នកទាំងអស់គ្នានឹងត្រូវរៀនភាសាជប៉ុន និងមុខវិជ្ជាជំនាញខ្លះ ។ឧទាហរណ៍ និស្សិតផ្នែកសេដ្ឋកិច្ចត្រូវរៀនគណិតវិទ្យា សេដ្ឋកិច្ចនយោបាយ ភូមិវិទ្យាជប៉ុន ប្រវត្តិវិទ្យាជប៉ុន រួមជាមួយនឹងភាសាជប៉ុន ។ប្រព័ន្ធសិក្សានៅខាងអូសាកានិងខាងតូក្យូហាក់ដូចជាខុសគ្នាទៀត នៅខាងតូក្យូ ការបង្រៀននិងការប្រលងមុខវិជ្ជាសេដ្ឋកិច្ចមានកំរិតខ្ពស់ជាងខាងអូសាកាច្រើន ដូច្នេះអ្នកដែលត្រូវមកសិក្សាភាសាជប៉ុនខាងតូក្យូ គួរតែរៀនសេដ្ឋកិច្ចជាមុនខ្លះជាការល្អ ជាពិសេសម៉ាក្រូសេដ្ឋកិច្ចនិងមីក្រូសេដ្ឋកិច្ច ។ ការបង្រៀននៅសាលាភាសាខាងតូក្យូច្រើនផ្តោតទៅលើម៉ាក្រូសេដ្ឋកិច្ច ។ នៅខែធ្នូនៃឆ្នាំដំបូងមុននឹងឈប់សំរាករដូវរងារ អ្នកទាំងអស់គ្នានឹងត្រូវជួបពិភាក្សាជាមួយគ្រូទទួលបន្ទុកដើម្បីរើស មហាវិទ្យាល័យសិក្សាមុខវិជ្ជាជំនាញ ។អ្នកទាំងអស់គ្នានឹងត្រូវរើសសាលាចំនួន៥តាមលេខរៀងដែលអ្នកទាំងអស់គ្នាចង់ទៅ បន្ទាប់មកគ្រូនឹងសំរេចថាតើអ្នកទាំងអស់គ្នានឹងត្រូវទៅមហាវិទ្យាល័យមួយណាតាមរយៈពិន្ទុប្រលងនៅសាលាភាសា ។ការប្រលងប្រជែងរើសមហាវិទ្យាល័យមានការប្រជែងគ្នាសម្បើមខ្លាំងណាស់ ។ក្រោយពីបញ្ចប់បរិញ្ញាប័ត្រមក អ្នកទាំងអស់គ្នាអាចសុំបន្តអាហារូបករណ៍ទៅវគ្គអនុបណ្ឌិតបានប៉ុន្តែត្រូវប្រលង ។តាមលទ្ធផលកន្លងមក ការសុំបន្តអាហារូបករណ៍នេះភាគច្រើនត្រូវបានអនុញ្ញាត្តិ ។

---

10 នៅក្នុងជំពូកនេះខ្ញុំបាទ អ្នករៀបរៀង បានព្យាយាមថែរក្សាអត្ថន័យដើមរបស់ម្ចាស់អត្ថបទ ។ ខ្ញុំបាទក៏សូមអភ័យទោសដល់លោក ញាន តុលា ដែលមិនបានចុះផ្សាយអត្ថបទរបស់លោក សំរាប់និស្សិតJDS ពីព្រោះខ្ញុំបាទយល់ថាអត្ថបទនោះមិនសូវជាត្រូវនឹងគោលបំនងនៃកូនសៀវភៅនេះ ។

## ២. យោបល់ណែនាំសំរាប់និស្សិតអាហារូបករណ៍ឧត្តមធ្យម

## ដោយសិស្សច្បងឧត្តមធ្យម  អែម  ចំណាប់

* នៅឆ្នាំដំបូងអ្នកទាំងអស់គ្នាស្នាក់នៅKomaba International Houseនៅតូក្យូដើម្បីរៀនភាសាជប៉ុន។ ឆមាសទី១រៀនតែភាសាជប៉ុន ប៉ុន្តែចាប់ពីឆមាសទី២មានភាសាអង់គ្លេស គណិត រូប គីមីវិទ្យាបន្ថែមទៀត។ ចំពោះភាសាជប៉ុន គួរតែយកសៀវភៅវចនានុក្រមខ្មែរ-ជប៉ុនលក់នៅហាងសៀវភៅនានាមក ។គួរតែយកវចនានុក្រមខ្មែរ-ជប៉ុនរបស់អ្នកគ្រូភាសាជនជាតិជប៉ុននៅសាលាសកលមកជាមួយ។ រីឯគណិតវិញគួរតែចេះខ្លះអំពី  Vector, Probability, Complex, ហើយចាំបាច់បំផុតគឺ  Matrix, Differential and Integral Calculus សំរាប់ឆ្នាំទី២ ។ចំពោះអ្នកដែលមានជំនាញខាងគីមី,គួរតែមានតារាងទំនាក់ទំនងរវាងអាស៊ីត,បាស,អំបិល, alkane, alkene, alkyne, alcohol, aldehyde, acid,… របស់គ្រូជ័យថាវី ពាក្យបច្ចេកទេសមួយចំនួនជាភាសាអង់គ្លេស និងសៀវភៅមួយចំនួន។

*  ចប់វគ្គភាសាជប៉ុន,អ្នកទាំងអស់គ្នាទៅសាលាបច្ចេកទេស  (college of technology) រៀងខ្លួន។ អ្នកទាំងអស់គ្នាគួរតែមានPostcards និងរបស់មួយចំនួនដើម្បីបង្ហាញពន្យល់ពីវប្បធម៌ខ្មែរ។ បន្ទាប់ពីចប់វគ្គមធ្យមពួកយើងអាចបន្តទៅថ្នាក់Bachelorហើយអាចបន្តអាហារូបករណ៍នេះតាមរយៈការសម្ភាសន៍របស់ក្រសួងអប់រំ។ ចំពោះខ្ញុំ ខ្ញុំបន្តការសិក្សាដោយទទួលអាហារូបករណ៍ពីក្រុមហ៊ុនក្នុងរយៈពេល ២ឆ្នាំ។

ប្រសិនបើមានសំនួរ,អ្នកអាចទាក់ទងតាមរយៈវិសាលរីមកខ្ញុំផ្ទាល់តាមរយៈ


EM Chamnab

Tokyo University of Agriculture and Technology

e-mail: emchamnab@hotmail.com

## ៣. យោបល់ណែនាំសំរាប់និស្សិតអាហារូបករណ៍វគ្គបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយសិស្សច្បងវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈ សុខ ថេងឌី

ជាបឋម ខ្ញុំបាទសូមចូលរួមចំណែកអបអរសាទរដល់អ្នកទាំងអស់គ្នាដែលបានទទួលជោគជ័យក្នុងការប្រលងទទួលយកអាហារូបករណ៍ជប៉ុន ។នេះជាឱកាសដ៏ល្អសំរាប់យើងដើម្បីទទួលយកនូវចំណេះដឹងថ្មីៗនិងបទពិសោធន៍ល្អៗដែលមិនអាចទទួលបាននៅស្រុកយើង ។ជាបន្តទៅនេះ ខ្ញុំនឹងលើកយកចំនុចខ្លះៗទាក់ទងនឹងការសិក្សារយៈពេល ៣ឆ្នាំ មកបកស្រាយអោយបានដឹងជាមុន ដើម្បីជាការត្រៀមខ្លួន ។

វគ្គបណ្តុះបណ្តាលវិជ្ជាជីវៈមានរយៈពេល៣ឆ្នាំ ក្នុងនោះឆ្នាំទីមួយតំរូវអោយសិក្សាភាសាជប៉ុន ចំនែកឯឆ្នាំទីពីរនិងទីបីតំរូវអោយសិក្សាមុខជំនាញជាមួយនិស្សិតជប៉ុននិងនិស្សិតបរទេសដទៃទៀត ហើយរាល់មេរៀននិងការពិសោធន៍ទាំងអស់ត្រូវប្រព្រឹត្តិទៅជាភាសាជប៉ុន ។ អាស្រ័យដូច្នេះហើយ យើងត្រូវព្យាយាមរៀនភាសាជប៉ុនអោយបានច្រើន ។បើសិនជាបានរៀនភាសាជប៉ុនមកមុនច្រើនក៏ជាការល្អ ។ចំពោះសាលាភាសាជប៉ុនមានបែងចែកជាពីរគឺតូក្យូនិងអូសាកា ។ខ្ញុំជឿថាអ្នកទាំងអស់គ្នាភាគច្រើននឹងត្រូវទៅសិក្សាភាសាជប៉ុននៅខាងអូសាកា ហើយចាប់ពីឆ្នាំទីពីរទៅនឹងត្រូវផ្លាស់មកតូក្យូ ។ត្រង់ចំនុចនេះសូមកុំព្រួយបារម្ភពីព្រោះថា មានសិស្សច្បងជាច្រើននៅចាំជួយជ្រោមជ្រែងនិងផ្តល់យោបល់ល្អៗ ។

ការសិក្សាភាសាជប៉ុននឹងប្រព្រឹត្តទៅរហូតដល់ខែមីនាឆ្នាំបន្ទាប់ ចំណែកឯផ្នែកជំនាញវិញនឹងត្រូវចាប់ផ្តើមនៅក្នុងខែមេសា ។យើងមានពេល១ខែដើម្បីត្រៀមខ្លួនផ្លាស់ទៅសាលាថ្មី ។ដូចដែលខ្ញុំបាននិយាយរួចហើយនៅខាងដើមនេះ រាល់មេរៀនទាំងអស់នឹងប្រព្រឹត្តទៅជាភាសាជប៉ុន ដូច្នេះតំរូវអោយយើងយល់ដឹងផ្នែកភាសាច្រើន ។ក្នុងកំឡុងពេលពីរបីខែដំបូងប្រហែលជាមានការលំបាកបន្តិចបន្តួចក្នុងការសិក្សាក៏ដូចជាក្នុងការសំរបទៅនឹងបរិដ្ឋានថ្មី ប៉ុន្តែត្រូវខិតខំប្រឹងប្រែង និងខំសួរយោបល់ពីសិស្សច្បង ។

វគ្គសិក្សានឹងបញ្ចប់នៅចុងឆ្នាំទីបី ពោលគឺកំឡុងខែមីនា ។រីឯអាហារូបករណ៍ក៏ត្រូវបញ្ចប់នៅពេលនោះដែរ ។ខ្ញុំគិតថាអ្នកទាំងអស់គ្នាក៏ដូចជារូបខ្ញុំដែរមានការចាប់អារម្មណ៍ខ្លាំងពីចំនុចនេះ ។ខ្ញុំសូមបញ្ជាក់ថា បន្ទាប់ពីបញ្ចប់ការ

សិក្សានេះ អ្នកទាំងអស់គ្នានឹងមានការយល់ដឹងពីសង្គមជប៉ុនច្រើន ។យើងអាចស្វែងរកការងារនៅតាមក្រុមហ៊ុននានា រឺក៏ អាចបន្តសិក្សាក៏បាន ។ក្នុងការស្វែងរកការងារ តំរូវអោយយើងយល់ដឹងអោយបានច្រើនអំពីមុខជំនាញដែលសិក្សានៅសាលា ។ប្រសិនបើបានប្រលងយកសញ្ញាប័ត្រផ្សេងៗ(Certificate) កាន់តែប្រសើរ ។សូមចងចាំថា យើងទាំងអស់គ្នាជាជនបរទេស ដូច្នេះការប្រាស្រ័យទាក់ទងគឺមានការលំបាក ម្យ៉ាងទៀតបច្ចុប្បន្នប្រទេសជប៉ុនកំពុងតែជួបវិបត្តិសេដ្ឋកិច្ច ដូច្នេះការស្វែងរកការងារធ្វើមានការលំបាកបន្តិច ។ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ អ្នកទាំងអស់គ្នាមានឱកាសច្រើន អ្វីៗទាំងអស់ស្ថិតនៅលើការប្រឹងប្រែងរបស់អ្នកទាំងអស់គ្នាផ្ទាល់ ។ចំណែកឯការបន្តការសិក្សានៅមហាវិទ្យាល័យ តំរូវអោយប្រលង Examination for Japanese University Admission for International Students និង Toefl ។ពោលគឺត្រូវត្រៀម ភាសាជប៉ុន ភាសាអង់គ្លេស គណិតវិទ្យា រូបវិទ្យា គីមីវិទ្យានិងប្រវត្តិសាស្ត្រពិភពលោក ។សូមបញ្ជាក់ថា ការប្រលងនេះមិនមែនជា ការប្រលងចូល មហាវិទ្យាល័យទេ ការប្រលងតាមមហាវិទ្យាល័យមានធ្វើឡើងដោយឡែកតាមមហាវិទ្យាល័យនានា ប៉ុន្តែអ្នកទាំងអស់គ្នាត្រូវការលទ្ធផលនៃការប្រលងនេះដើម្បីប្រលងចូលមហាវិទ្យាល័យ ។ ចំពោះអាហារូបករណ៏ដែលយើងបានទទួលក្នុងកំឡុង ៣ឆ្នាំនេះមិនអាចបន្តបានទៀតទេ ប៉ុន្តែយើងអាចប្រលងយកអាហារូបករណ៏ផ្សេងៗបាន ។

ខាងក្រោមនេះជារបស់គេហទំព័រខ្លះដែលមានពិតមានផ្សេងៗទាក់ទងទៅនឹងការសិក្សានៅជប៉ុន ។

- http://www.gakkou.net
- http://www.aiej.or.jp

ជាទីបញ្ចប់នេះ ខ្ញុំសូមជូនពរ និងសង្ឃឹមថាបានជួបអ្នកទាំងអស់គ្នាក្នុងពេលឆាប់ៗនេះ ។

បើសិនជាមានសំនួរអ្វី សូមទាក់ទងមកខ្ញុំផ្ទាល់តាមអ៊ីមេល sokthangdy@hotmail.com